ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ
នាយកដ្ឋានបច្ចេកវិទ្យាគមនាគមន៍
និងព័ត៌មាន

# សេចក្តីជូនព័ត៌មាន

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជានឹងដឹកនាំគណៈប្រតិភូជាន់ខ្ពស់អញ្ជើញចូលរួម «វេទិកាខ្សែក្រវ៉ាត់ និងផ្លូវសម្រាប់កិច្ចសហប្រតិបត្តិការអន្តរជាតិ» ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី ១៤-១៥ ខែឧសភា ឆ្នាំ២០១៧ នៅទីក្រុងប៉េកាំង តបតាមអញ្ជើញរបស់ឯកឧត្តម ហ៊្សី ជីនពីង ប្រធានាធិបតីនៃសាធារណរដ្ឋប្រជាមានិតចិន។

សម្តេចតេជោ ហ៊ុន សែន នឹងចូលរួមជាមួយប្រមុខរដ្ឋ/រដ្ឋាភិបាលដ៏ទៃទៀតក្នុងកិច្ចប្រជុំតុមូលសម្រាប់ថ្នាក់ដឹកនាំ ដែលមានឯកឧត្តម ហ៊្សី ជីនពីង ប្រធានាធិបតីសាធារណរដ្ឋប្រជាមានិតចិនជាប្រធាន ហើយសម្តេចតេជោ ហ៊ុន សែននឹងថ្លែងសុន្ទរកថាក្នុងកិច្ចប្រជុំដែលមានមូលបទ «ថាមពលរួមនៃគោលនយោបាយ ដើម្បីភាពជាដៃគូជិតស្និទ្ធ» និងក្នុងកិច្ចប្រជុំដែលមានមូលបទ «ពង្រឹងចំណងទាក់ទងរវាងប្រជាជន និងប្រជាជន» ។

នៅទន្ទឹមនឹងកិច្ចប្រជុំនេះ សម្តេចតេជោ នឹងមានជំនួបទ្វេភាគីជាមួយឯកឧត្តម អ៊ែដេណឺបាត ចាហ្គាល់ទុលហ្គា (Erdenebat Jargaltulga)នាយករដ្ឋមន្ត្រីម៉ុងហ្គោលី និងទទួលការចូលជួបសម្តែងការគួរសមពីប្រធានក្រុមហ៊ុនរបស់ចិនមួយចំនួនផងដែរ។

បន្ទាប់ពីបញ្ចប់វេទិកានេះ សម្តេចតេជោ ហ៊ុន សែន និងគណៈប្រតិភូ នឹងបន្តបំពេញទស្សនកិច្ចផ្លូវការនៅប្រទេសចិនពីថ្ងៃទី ១៦ ដល់១៧ ខែឧសភា ឆ្នាំ២០១៧ តបតាមការអញ្ជើញរបស់រដ្ឋាភិបាលចិន។

ក្នុងអំឡុងពេលទស្សនកិច្ចនេះ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នឹងមានជំនួបដោយឡែកៗពីគ្នា ជាមួយថ្នាក់ដឹកនាំរបស់ចិនជាច្រើនរូប ដូចជា ឯកឧត្តម ហ៊្សី ជីនពីង (Xi Jinping) ប្រធានាធិបតីនៃសាធារណរដ្ឋប្រជាមានិតចិន ឯកឧត្តម លី ខឺឈាង (Li Keqiang) នាយករដ្ឋមន្ត្រី ឯកឧត្តម ចាង តេជាំង (Zhang Dejiang) ប្រធានសភាតំណាងប្រជាជនចិន និង ឯកឧត្តម យូ ជឹងស៊ឹង (Yu Zhengsheng) ប្រធានសភាប្រឹក្សានយោបាយចិន។

ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ហោ ណាំហុង និងឯកឧត្តមទេសរដ្ឋមន្ត្រី ប្រាក់ សុខុន រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ នឹងអមដំណើរសម្តេចតេជោ រួមជាមួយឥស្សរជនកម្ពុជាមួយចំនួនទៀត ដូចជា៖

- ឯកឧត្តម អូន ព័ន្ធមុនីរ័ត្ន ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ឯកឧត្តម ស៊ុន ចាន់ថុល ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន
- ឯកឧត្តម ប៉ាន សូរស័ក្តិ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និង
  សមាជិករាជរដ្ឋាភិបាលកម្ពុជាដទៃទៀត។

នៅចុងបញ្ចប់នៃដំណើរទស្សនកិច្ចនេះ ឯកសារមួយចំនួននឹងត្រូវបានចុះហត្ថលេខា។

ក្នុងអំឡុងពេលទស្សនកិច្ចនៅប្រទេសចិន សម្តេចតេជោ ក៏នឹងជួបសំណេះសំណាលជាមួយ សិស្ស/និស្សិតកម្ពុជាដែលកំពុងសិក្សានៅប្រទេសចិន ព្រមទាំងផ្តល់បទសម្ភាសន៍ដល់ក្រុមអ្នកសារ-ព័ត៌មានចិន ព្រមទាំងអញ្ជើញទៅទីក្រុងស៊ីអាន នៃខេត្តសានស៊ី ដើម្បីធ្វើជាអធិបតីនៃការបើកសម្ពោធ មជ្ឈមណ្ឌលពាណិជ្ជកម្មកម្ពុជា។/.

ភ្នំពេញ, ថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០១៧